International Labour Organization | BetterWork | ILR School

ILO brief

# គម្រោងការងារសមរម្យក្នុងសង្វាក់ផ្គត់ផ្គង់សំលៀកបំពាក់ក្នុងតំបន់អាស៊ី

ខែ ឧសភា ឆ្នាំ២០២១

## បទបញ្ញត្តិដែលមានប្រសិទ្ធភាព? ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរក្នុងប្រទេសបង់ក្លាដេស កម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម

បទប្បញ្ញត្តិបរិស្ថានការពារធនធានបរិស្ថានផង និងជីវភាពរស់នៅរបស់សហគមន៍ដែលពឹងអាស្រ័យលើធនធានទាំងនេះផង។ ការវិភាគនេះវាយតម្លៃលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សម្រាប់ម្ចាស់គម្រោងឧស្សាហកម្ម ក្នុងប្រទេសបង់ក្លាដែស កម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម។ របាយការណ៍នេះរកឃើញថា គេអាចសម្រេចបានលទ្ធផលបរិស្ថានកាន់តែប្រសើរ តាមរយៈការបង្កើនការយល់ដឹងដល់ម្ចាស់គម្រោងអំពីទំនាក់ទំនងរវាងការគ្រប់គ្រងបរិស្ថាន (ដែលសម្របសម្រួលដោយដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) និងការអភិវឌ្ឍដោយចីរភាព។

## សេចក្ដីសង្ខេប


បទបញ្ញត្តិបរិស្ថានផ្ដល់ការការពារដល់ទ្រព្យសម្បត្តិបរិស្ថាន និងរបរចិញ្ចឹមជីវិតរបស់សហគមន៍ដែលអាស្រ័យផលពីទ្រព្យសម្បត្តិទាំងនេះ។ ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) ជាយន្តការដ៏សំខាន់មួយសម្រាប់និយ័តកម្មបរិស្ថាន និងជាឧបករណ៍ដ៏សំខាន់មួយផងដែរសម្រាប់ការរៀបចំផែនការ និងការធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ការវាយតម្លៃនេះមានគោលបំណងធានាការការពារ និងការអភិរក្សធនធានបរិស្ថាន និងធនធានធម្មជាតិក្នុងដំណើរការអភិវឌ្ឍឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានគឺជាឧបករណ៍រៀបចំផែនការផង និងជាយន្តការធ្វើសេចក្ដីសម្រេចចិត្តផង។ ប្រទេសទាំង ៤ ដែលលើកមកវិភាគក្នុងរបាយការណ៍នេះ សុទ្ធតែមានប្រព័ន្ធវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន(បង់ក្លាដេស កម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម) ដោយប្រព័ន្ធក្នុងប្រទេសនីមួយៗសុទ្ធតែមានចំណុចខ្លាំង និងចំណុចខ្សោយ។ក្នុងប្រទេសទាំង ៤ នេះ ប្រព័ន្ធវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ត្រូវបានគាំទ្រ (ឬក្នុងករណីប្រទេសកម្ពុជា នឹងត្រូវបានគាំទ្រ) ដោយក្របខណ្ឌគតិយុត្តិដ៏រឹងមាំដោយមានការកំណត់យ៉ាងច្បាស់លាស់នូវដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងការធ្វើសេចក្ដីសម្រេចចិត្តបែបប្រតិភូកម្ម។ការវិភាគប្រព័ន្ធវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានក្នុងប្រទេសទាំង ៤ នេះបង្ហាញថា ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ត្រូវបានចាត់ទុកជាដំណើរការរយៈពេលខ្លីក្នុងការសម្រេចបានការអនុម័តលើការអភិវឌ្ឍ ជាជាងការប្ដេជ្ញាចិត្តជាបន្តបន្ទាប់ក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថានដោយសារសកម្មភាពឧស្សាហកម្ម។ ការមានលក្ខខណ្ឌតម្រូវផ្លូវច្បាប់សម្រាប់ប្រព័ន្ធវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានមិនប្រាកដថាអាចកាត់បន្ថយផលប៉ះពាល់បរិស្ថានបានឡើយ។

ប្រសិទ្ធភាពនៃប្រព័ន្ធវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានអាស្រ័យលើវិសាលភាពនៃប្រព័ន្ធនេះ កាប៉ាស៊ីតេរបស់អ្នកចូលរួមក្នុងការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ដំណើរការសម្រាប់ការពិនិត្យ

ពិច័យ និងតាមដានការវាយតម្លៃ និងកម្រិតឥទ្ធិពលរបស់អ្នកពាក់ព័ន្ធក្នុងដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ក៏ដូចជាការអនុម័ត និងការផ្តល់អាជ្ញាប័ណ្ណប្រតិបត្តិការ។

ការវិភាគបែបប្រៀបធៀបនេះបានរំលេចចំណុចខ្សោយ ក្នុងប្រព័ន្ធវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានរបស់ប្រទេសទាំង ៤ ដូចខាងក្រោម ៖

- លទ្ធភាពទទួលបានជំនាញបច្ចេកទេស និងបទពិសោធន៍ដែលចាំបាច់សម្រាប់ការអនុវត្ត និងអនុម័តការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន
- ការរកបាន និងគុណភាពនៃទិន្នន័យដើមគ្រាដើម្បីកំណត់រក និងប៉ាន់ប្រមាណទំហំនៃផលប៉ះពាល់បរិស្ថានគិតជាបរិមាណ
- កង្វះការយល់ដឹង និងបទពិសោធន៍របស់តួអង្គឧស្សាហកម្ម ស្តីពីសារៈសំខាន់នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងភាពចាំបាច់ក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងរបៀបដែលចំណុចនេះផ្សារភ្ជាប់នឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង
- ប្រព័ន្ធចែករំលែកចំណេះដឹង និងការរៀនសូត្រជារួមដើម្បីគាំទ្រដល់ការកែលម្អការអនុវត្តដោយផ្អែកលើបទពិសោធន៍កន្លងមក។

ការវិភាគនេះបង្ហាញថា តួអង្គក្នុងគម្រោងឧស្សាហកម្មមានតួនាទីច្បាស់លាស់មួយក្នុងដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ហើយគេអាចសម្រេចបានលទ្ធផលបរិស្ថានកាន់តែប្រសើរតាមរយៈការបង្កើនយល់ដឹងក្នុងចំណោមតួអង្គពាក់ព័ន្ធដែលផ្សារភ្ជាប់រវាងការគ្រប់គ្រងបរិស្ថាន (សម្របសម្រួលដោយដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន) និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ សកម្មភាពដែលស្នើឡើងពីរបាយការណ៍នេះ គឺការសហការជាមួយតួអង្គឧស្សាហកម្មតាមរយៈគម្រោងការងារសមរម្យក្នុងសង្វាក់ផ្គត់ផ្គង់សំលៀកបំពាក់នៅតំបន់អាស៊ី ដើម្បីបង្កើនការយល់ដឹងស្តីពីដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងទំនាក់ទំនងរវាងការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ របាយការណ៍នេះក៏គូសបញ្ជាក់ផងដែរនូវឱកាសសម្រាប់ការអភិវឌ្ឍជំនាញបន្ថែមទៀតសម្រាប់អ្នកជំនាញដែលចូលរួមក្នុងការអនុវត្ត និងអនុម័តការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន។ មានគម្លាតក្នុងការចែករំលែកចំណេះដឹង និងការរៀនសូត្រពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានកន្លងមកនិងកង្វះការពិនិត្យមើលបទពិសោធន៍នាពេលកន្លងមកដើម្បីប្រៀបធៀបផលប៉ះពាល់បរិស្ថានជាក់ស្តែងដោយសារគម្រោងឧស្សាហកម្ម និងផលប៉ះពាល់ដែលបានព្យាករណ៍ និងការចែករំលែក និងប្រើប្រាស់ចំណេះដឹងនេះដើម្បីពង្រឹងសកម្មភាពវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននាពេលអនាគត។ ការចែករំលែកចំណេះដឹង និងការរៀនសូត្រក្នុងចំណោមក្រុមអ្នកជំនាញ (ទីប្រឹក្សាបៃតង/ទីប្រឹក្សាសេវាធុរកិច្ចដែលមានបពិសោធន៍ និងចំណេះដឹងទូលំទូលាយ) តាមបណ្តាប្រទេសទាំង ៤ នេះ និងទូទាំងតំបន់អាស៊ី នឹងរួមចំណែកដល់ការកែលម្អគុណភាពនៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន។

**ព័ត៌មានទំនាក់ទំនង**

**ការិយាល័យ ILO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច**
United Nations Building
Rajdamnern Nok Avenue
Bangkok 10200, Thailand

T: +66 2288 1234
F: +66 2280 1735
E: BANGKOK@ilo.org
W: www.ilo.org/asiapacific

©អង្គការអន្តរជាតិខាងការងារ ឆ្នាំ ២០២១